# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៥-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៥៥ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងអស់លោក ចំនួន ០២ រូប ៧៧២៦

២៥-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៥៦ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះលោកជំទាវ និងអ្នកអង្គម្ចាស់ ចំនួន១១រូប ៧៧២៧

២៥-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៥៧ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះលោកឧត្តមសេនីយ៍ត្រី ចំនួន ០២ រូប ៧៧២៨

២៩-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៦៤ ស្តីពីការតែងតាំង លោក **ខឹម យាន** ជា ឧកញ៉ា ៧៧២៩

២៩-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៦៥ ស្តីពីការតែងតាំង លោក **ចៅ ភិរិទ្ធ** ជា ឧកញ៉ា ៧៧៣០


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


០១-១២-២០០៦ -អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ស្តីពីការរៀបចំបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សំរាប់មន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ៧៧៣១

០១-១២-២០០៦ -អនុក្រឹត្យលេខ ៧៥៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៧៤០

០១-១២-២០០៦ -អនុក្រឹត្យលេខ ៧៥៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៧៤១

០១-១២-២០០៦ -អនុក្រឹត្យលេខ ៧៥៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៧៤២

០១-១២-២០០៦ -អនុក្រឹត្យលេខ ៧៥៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៧៤៣

០១-១២-២០០៦ -អនុក្រឹត្យលេខ ៧៥៧ អនក្រ.តត ស្តីពីការដាក់វិន័យចំពោះមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ ៧៧៤៤


### ២.សេចក្តីសំរេច


០៤-១២-២០០៦ -សេចក្តីសំរេចលេខ ៥៣ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៧៧៤៨

## IV~ការិយាល័យ/ក្រសួង

### ១~ធនាគារជាតិ នៃ កម្ពុជា


១៣-៩-២០០៦ -ប្រកាសលេខ ធ៧.០៦-២០៧ ប្រក ស្តីពីការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ចំពោះធនាគារពាណិជ្ជ ៧៧៤៩

១៣-៩-២០០៦ -ប្រកាសលេខ ធ៧.០៦-២០៨ ប្រក ស្តីពីការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ចំពោះធនាគារឯកទេស ៧៧៥៣

១៣-៩-២០០៦ -ប្រកាសលេខ ធ៧.០៦-២០៩ ប្រក ស្តីពីការកែសម្រួលប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៧៧៥៧

១៣-៩-២០០៦ -ប្រកាសលេខ ធ៧.០៦-២១០ ប្រក ស្តីពីការកែសម្រួលប្រកាសស្តីពីសេហ៊ុយបង្កើនដើមទុនសំរាប់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៧៧៦១

១៣-៩-២០០៦ -ប្រកាសលេខ ធ៧.០៦-២១១ ប្រក ស្តីពីកាលបរិច្ឆេទផ្ញើរបាយការណ៍ របស់ធនាគារពាណិជ្ជ និងធនាគារឯកទេស ៧៧៦៥

១៣-៩-២០០៦ -ប្រកាសលេខ ធ៧.០៦-២១២ ប្រក ស្តីពីកាលបរិច្ឆេទផ្ញើរបាយការណ៍ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៧៧៧១

០៣-១១-២០០៦ -ប្រកាសលេខ ធ៧.០៦-២២៦ប្រក ស្តីពីការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ៧៧៧៦


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម


០៤-១២-២០០៦ -ប្រកាសលេខ ១៨៧ ប្រក.ធទឧ ស្តីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវឯកសារល័ក្ខខ័ណ្ឌយោង (Term of Reference,TOR) សម្រាប់ការងាររបស់ការិយាល័យគ្រប់គ្រងគំរោង ប្រចាំក្រសួងធនធានទឹក និងឧតុនិយម ៧៧៨៧


### ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា


០២-១១-២០០៦ -សេចក្តីជូនដំណឹងលេខ ៤០២៨ អយក.សជណ ៧៨០៣


### ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាតធី ម៉ាឃីធីង ខូ អិលធីឌី** ៧៨០៤

០៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សំ ថ្រាខើរ អ៊ិនវេសមេន** ៧៨០៦

០៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិកស៍ ភី មីនើរ៉ល** ៧៨០៨

០៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហូតិច គ្រុប** ៧៨១០

០៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ ធី ឌី អ៊ិមផត អិចផត ខូ អិលធីឌី** ៧៨១២

០៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាប់ប៊ែលយូ.ដាប់ប៊ែលយូ.ទូត** ៧៨១៤

០៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៥៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថប ស័យ្យែរ ម៉ាល់ធី** ៧៨១៦

០៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថប វ៉ំន ភ្លាស (ខេមបូឌា)** ៧៨១៨

០៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីម គូច វឌ្ឍនៈ ខនស្ត្រាក់សិន** ៧៨២០

០៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមៀ ឌី សេគ្រេតធ្រី លីមីធីត** ៧៨២២

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៥៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

### ប្រោសព្រះរាជទាន

-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

-ឯកឧត្តម ឧត្តមសេនីយ៍ឯក ចៅ តិរុណា

-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

-លោក គីម ខួន

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រ៧.០៦១១.៤៨១

លេខ : ៤៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[signature]

ឃ.ល. ឃឹុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៥៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

នូវ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :
១-លោកជំទាវ អ៊ុង គន្ធាផាវី
២-លោកជំទាវ យឹម ចំរើន
៣-លោកជំទាវ សោម គឹមសួគ៌
៤-លោកជំទាវ យូ អយ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :
១-លោកជំទាវ អ៊ឹម ស៊ីថៃ
២-លោកជំទាវ ច័ន្ទ សូរិយ៍
៣-លោកជំទាវ សាន អរុណ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :
១-លោកជំទាវ ញ៉ែម មរកត
២-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ខេមាចត្តី
៣-លោកជំទាវ ស៊ី ដេហ្វីន
៤-លោកជំទាវ គួប ម៉ារីយ៉ាស់

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ជករ

ជា ស៊ីម

៣រ៧.០៦១១.៤៩២

លេខ : ៤៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យន្ត ឌីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៥៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

-លោកឧត្តមសេនីយ៍ត្រី ជុំ សុយ៉ាត

-លោកឧត្តមសេនីយ៍ត្រី គាំ សុខុន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

គ្លង់ព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រ៧.០៦១១.៤៨៣

លេខ ៤៣៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៦៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

## តែងតាំង

លោក ជឹម យាន

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៦
ត្រូវព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៣រ/ល.០៦១១.៤៩០

ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ : ៤៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៦៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

## តែងតាំង

លោក ចៅ ភិរុទ្ធ

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៦

ត្នូវព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ចរល.០៦១១.៤៩១

លេខ : ៤៤០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ សំរាប់មន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម

*************

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សំរេច**

**មាត្រា១.** អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្មបង្កើតឯកសណ្ឋាន (រួមមានទាំងសញ្ញាសម្គាល់របស់ក្រសួងពាណិជ្ជកម្មនិងស្លាកសម្គាល់ឈ្មោះមន្ត្រីរាជការបំពាក់លើឯកសណ្ឋាន) សំរាប់មន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្មប្រើប្រាស់ក្នុងពេលប្រតិបត្តិការងារ លើកលែងតែមន្ត្រីរាជការនៃនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" មានឯកសណ្ឋានដោយឡែក ។

**មាត្រា២.** ឯកសណ្ឋានសំរាប់សម្គាល់មន្ត្រីរាជការរបស់ក្រសួងពាណិជ្ជកម្មត្រូវបានកំណត់ជាបីថ្នាក់ដូចតទៅ ៖

**ក-ឯកសណ្ឋានមន្ត្រីពាណិជ្ជកម្មចាប់ពី អនុប្រធាននាយកដ្ឋានឡើង**

**-សំរាប់បុរស ៖**

. **ខោជើងវែង ៖** ពណ៌សណ្តែកខ្មៅ ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លឺខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀត នៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ ៖** អាវដៃខ្លី កបើកថ្នេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះមានគំរបរាងស្លឹកពោធិ មានឡេវពណ៌មាសរូបព្រះសង្ហា ។

**-សំរាប់នារី ៖**

.**ខោជើងវែង ៖** ពណ៌សណ្តែកខ្មៅ ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លឺខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀត នៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ ៖** អាវដៃខ្លី កឌុប ថ្នេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះ មានគំរបរាងស្លឹកពោធិ មានឡេវពណ៌មាសរូបព្រះសង្ហា ។

**ខ-ឯកសណ្ឋានមន្ត្រីពាណិជ្ជកម្មថ្នាក់ការិយាល័យ**

**-សំរាប់បុរស ៖**

.**ខោជើងវែង ៖** ពណ៌សណ្តែកខ្មៅ ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លឺ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀត នៅ ចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ ៖** អាវដៃខ្លី កបើកថ្នេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះ មានគំរបរាងស្លឹកពោធិ ។

**- សំរាប់នារី ៖**

. **ខោជើងវែង ៖** ពណ៌សណ្តែកខ្មៅ ផលិតពីក្រណាត់តេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ជីបភ្លឺខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀត នៅចំហៀង ដេរបង្កប់តាមថ្នេរ" ។

. **អាវ ៖** អាវដៃខ្លី កឌុបថ្នេរឌុប មានជីបចង្កេះ ពណ៌និងសាច់ក្រណាត់ដូចខោ មានហោប៉ៅបួន ដេរប៉ះ មានគំរបរាងស្លឹកពោធិ ។

**គ-ឯកសណ្ឋានមន្ត្រីពាណិជ្ជកម្ម**

**- សំរាប់បុរស :**

. **ខោជើងវែង :** ពណ៌សណ្តែកខ្ចី ផលិតពីក្រណាត់តេហ្កាលឡែន ចង្កេះត ថ្ពេរបង្កប់ជីបភ្ជិខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្ពេរ" ។

. **អាវ :** អាវដៃវែងកបើកថ្ពេរឌុបមានពណ៌និងសាច់ក្រណាត់ដូចខោមានហោប៉ៅពីរដេរប៉ះ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ កាត់ស្រុងវែងជើងត្រង់ ។

**- សំរាប់នារី :**

. **ខោជើងវែង :** ពណ៌សណ្តែកខ្ចី ផលិតពីក្រណាត់តេហ្កាលឡែន ចង្កេះត ថ្ពេរបង្កប់ជីបភ្ជិខាងមុខ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្ពេរ" ។

. **អាវ :** អាវដៃខ្លីកឌុបថ្ពេរឌុប មានជីបចង្កេះ ពណ៌និងសាច់ក្រណាត់ដូចខោមានហោប៉ៅពីរ ដេរប៉ះ មានគំរបរាងស្លឹកពោធិ កាត់ស្រុងវែងជើងត្រង់ ។

**ឃ-ស្លាកសម្គាល់ឈ្មោះមន្ត្រី :**

ស្លាកសម្គាល់ឈ្មោះមន្ត្រីរាជការ មានរាងបួនជ្រុងទ្រវែង បណ្តោយ ១០សង់ទីម៉ែត្រ ទទឹង០២សង់ទីម៉ែត្រ ធ្វើពីជាតិជ័ររឹង មានរូបសញ្ញាសម្គាល់ក្រសួងពាណិជ្ជកម្ម នៅចំហៀងខាងស្តាំ និងចំហៀងខាងឆ្វេង មានសរសេរឈ្មោះមន្ត្រី ជាអក្សរខ្មែរនៅជួរលើ និងអត្តលេខជាលេខសកលនៅជួរក្រោម ។ ស្លាកសម្គាល់នេះសម្រាប់រំពាក់លើគម្របហោប៉ៅខាងស្តាំ ចែកជាបីថ្នាក់ :

- **ថ្នាក់អនុប្រធាននាយកដ្ឋានឡើង :** បន្ទះជ័រជាស្លាកសម្គាល់ឈ្មោះមន្ត្រី មានផ្ទៃពណ៌ទឹកប៊ិច ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌មាសបិទជិត ។ អក្សរ និងអត្តលេខសរសេរពណ៌មាស ។
- **ថ្នាក់ការិយាល័យ :** បន្ទះជ័រជាស្លាកសម្គាល់ឈ្មោះមន្ត្រី មានផ្ទៃពណ៌ទឹកប៊ិច ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌ប្រាក់បិទជិត ។ អក្សរ និងអត្តលេខសរសេរពណ៌ប្រាក់ ។
- **ថ្នាក់មន្ត្រី :** បន្ទះជ័រជាស្លាកសម្គាល់ឈ្មោះមន្ត្រី មានផ្ទៃពណ៌ទឹកសមុទ្រ ។ អក្សរនិងអត្តលេខសរសេរពណ៌ស ។

**មាត្រា៣.-** ឯកសណ្ឋានដូចមានចែងក្នុងមាត្រា២ ខាងលើនេះ ត្រូវភ្ជាប់នូវរូបសញ្ញាសម្គាល់របស់ក្រសួងពាណិជ្ជកម្ម នៅលើដើមដៃអាវខាងស្តាំ សំរាប់មន្ត្រីរាជការស្លៀកពាក់ ក្នុងពេលចុះបំពេញបេសសកម្មការងារ ឬក្នុងពិធីផ្លូវការផ្សេងៗរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា៤.** ឯកសណ្ឋានសំរាប់មន្ត្រីរាជការ ផ្តល់ជូនចំនួន ០២សំរាប់ (ពីរសំរាប់) ក្នុងរយៈពេលមួយឆ្នាំ ។

**មាត្រា៥.** ជនណាក្លែងបន្លំខ្លួនស្លៀកពាក់ឯកសណ្ឋាន ដោយមានភ្ជាប់ស្លាកសម្គាល់ឈ្មោះ និងសញ្ញាសម្គាល់របស់ក្រសួងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា៦.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន និង គ្រប់ខេត្ត ក្រុង ពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០៦

## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

## ក្រសួងពាណិជ្ជកម្ម

### ឯកសណ្ឋានសម្រាប់ថ្នាក់នាយកដ្ឋាន

បុរស



នារី



## ឧបសម្ព័ន្ធទី២

### នៃអនុក្រឹត្យលេខ១៣៨ អនក្រ.បក   ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៦

### ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

### ក្រសួងពាណិជ្ជកម្ម

### ឯកសណ្ឋានសម្រាប់ថ្នាក់ការិយាល័យ

បុរស    នារី



# ឧបសម្ព័ន្ធទី៣

## នៃអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៦
## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ
## ក្រសួងពាណិជ្ជកម្ម

## ឯកសណ្ឋានសម្រាប់មន្ត្រី

បុរស



នារី



# ឧបសម្ព័ន្ធទី៤

## នៃអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៦

## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

## ក្រសួងពាណិជ្ជកម្ម

## សញ្ញាសម្គាល់ឈ្មោះមន្ត្រីរាជការ

ក- ថ្នាក់នាយកដ្ឋាន




ខ- ថ្នាក់ការិយាល័យ




គ- មន្ត្រី



# ឧបសម្ព័ន្ធទី៥

## នៃអនុក្រឹត្យលេខ១៣៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៦

## ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់មន្ត្រីរាជការ

## ក្រសួងពាណិជ្ជកម្ម

## ផ្លាកសំគាល់សញ្ញាក្រសួងពាណិជ្ជកម្ម

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៤៣.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **Dr.Thomas Engelhardt , GTZ - Country Director Phnom Penh , Cambodia** ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការជួយអភិវឌ្ឍន៍ និងកែទម្រង់លើគ្រប់វិស័យ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន ០៤រូប ដែលមានស្នាដៃល្អក្នុងកាធ្វើសហប្រតិបត្តិការ ជាមួយកងកម្លាំងវិស្វកម្ម នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដើម្បីសម្រេចនូវភារកិច្ច ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ-ស្ពាន ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោក | **ឌី ឡាំថា** | ប្រធានការិយាល័យវិនិយោគ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ២-លោក | **ឌាន់ សុខេន** | អភិបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ |
| ៣-លោក | **ជួប សេដ្ឋា** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ធំ |
| ៤-លោក | **ម៉ៅ ឡាំខ** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ... ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើរបស់ឯកឧត្តម កែវ ពុទ្ធរស្មី ឧបនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងជំនួយការ ឯកឧត្តម **កែវ ពុទ្ធរស្មី** ឧបនាយករដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោមៈ

១-លោកស្រី **នឹម វ៉ាន់នី** ជាជំនួយការឯកឧត្តម **កែវ ពុទ្ធរស្មី** មានឋានៈស្មើ អគ្គនាយករង ។

២-លោក **ប៊ុត សួនកុសល** ជាជំនួយការឯកឧត្តម **កែវ ពុទ្ធរស្មី** មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានតែងតាំង លោកស្រី **រស់ សុវត្ថា** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**មាត្រា ២** : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះ ហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤៧ អនក្រ.បក.

## អនុក្រឹត្យ
## ស្តីពី
## ការដាក់វិន័យចំពោះមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ

~~~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០០/១៣៥ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីភ្នាក់ងាររដ្ឋបាល
~~~~~~~~~~

- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់

## សម្រេច

**មាត្រា១ :** ត្រូវបានដាក់វិន័យចំពោះមន្ត្រីនគរបាលជាតិ និងមន្ត្រីរាជការស៊ីវិល :

១-លោក **ឈឿន សុខុម** បច្ចុប្បន្នស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ

២-លោក **ហ៊ីច គីមហេង** បច្ចុប្បន្នប្រធានសាខាគយ និងរដ្ឋាករខេត្តបន្ទាយមានជ័យ

៣-លោក **សិរិទ្ធិ អេង** បច្ចុប្បន្នអនុប្រធានសាខាគយ និងរដ្ឋាករខេត្តបន្ទាយមានជ័យ

៤-លោក **ខាំ តំនួរជន្ទ** បច្ចុប្បន្នអនុប្រធានទទួលបន្ទុករួមគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ

៥-លោក **អាន អន្ទារ៉ា** បច្ចុប្បន្នអនុប្រធានគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ

៦-លោក **កង ធឿន** បច្ចុប្បន្នអនុប្រធានគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ

៧-លោក **ប៊ូ គុន** បច្ចុប្បន្នអនុប្រធានទទួលបន្ទុករួមគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

៨-លោក **សំ ធី** បច្ចុប្បន្នអនុប្រធានគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

៩- លោក **នួន ម៉ុនលី** បច្ចុប្បន្នមន្ត្រីគយបម្រើការងារនៅសាខាគយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ

១០-លោក **សុខ ភារម្យ** បច្ចុប្បន្នមន្ត្រីគយបម្រើការងារនៅសាខាគយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ

តាមរូបភាពផ្លាស់ចេញដោយបង្ខំពីមុខងារបច្ចុប្បន្ន ហើយបន្ថែមលើនេះដាក់ឱ្យនៅទំនេរគ្មានបៀវត្សរយៈពេល ៦ខែ ដោយមូលហេតុសាមីខ្លួនខ្វះខាតក្នុងកាតព្វកិច្ចបំពេញការងារ ។

**មាត្រា២ :** ត្រូវបានដាក់វិន័យចំពោះមន្ត្រីរាជការស៊ីវិល :

១-លោក **ម៉ុក ច័ន្ទពុទ្ធា** បច្ចុប្បន្នប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ

២-លោក **អ៊ិន ផាត** បច្ចុប្បន្នប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

តាមរូបភាពស្តីបន្ទោស ដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន និងផ្លាស់ចេញដោយបង្ខំពីមុខងារបច្ចុប្បន្ន ដោយមូលហេតុសាមីខ្លួនខ្វះខាតក្នុងកាតព្វកិច្ចបំពេញការងារ ។

**មាត្រា៣ :** ត្រូវបានដាក់វិន័យចំពោះមន្ត្រីរាជការស៊ីវិល :

១-លោក **កង គីមលីន** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ

| | |
|---|---|
| ២-លោក ហួរ ឡេង | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ |
| ៣-លោក ឆាយ មូ | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ |
| ៤-លោក ហែម ទឿន | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ |
| ៥-លោក អ៊ុំ ស៊ីផល | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ |
| ៦-លោក គីម សាគល | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ខេត្តបន្ទាយមានជ័យ |
| ៧-លោក សំ ស៊ីនិត | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្ររទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ៨-លោក ថៃ ធី | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ៩-លោក សំ គីមរោង | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១០-លោក ជីវ សុខេន | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១១-លោក តែម ឃឿន | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១២-លោក រិទ្ធិ ទឿន | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១៣-លោក ចក់ ចឿន | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១៤-លោក ទ្រាម នឿង | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១៥-លោក ឃីម ថៃ | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១៦-លោក យ៉ុង គុន | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១៧-លោក សៅ សារ៉ុន | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |
| ១៨-លោក ជួប ធី | បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ |

១៩-លោក **ហ៊ុន សារឿន** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២០-លោក **ម៉ុយ ខ្មែរ** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២១-លោក **ហោ ឆឹងហេង** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២២-លោក **ញ៉ន លី** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២៣-លោក **នឿន អឺន** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២៤-លោក **កែវ កុសល់** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២៥-លោក **ហួន សាម៉ុន** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២៦-លោក **នួន ធី** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

២៧-លោក **ជា ម៉ុនធឿន** បច្ចុប្បន្នភ្នាក់ងារគយ និងរដ្ឋាករប្រចាំទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ

តាមរូបភាពស្តីបន្ទោស ដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន និងផ្លាស់ចេញដោយបង្ខំពីមុខងារបច្ចុប្បន្ន ដោយមូលហេតុសាមីខ្លួនខ្វះខាតក្នុងកាតព្វកិច្ចបំពេញការងារ ។

**មាត្រា៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :.....................

## សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត./ ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលរវាងនាយករដ្ឋមន្ត្រីទាំង៣ ស្តីពីការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ និងវៀតណាម ពីថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៦ នៅទីក្រុងដាឡាត់ សាធារណរដ្ឋសង្គមនិយមវៀតណាម រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល :</u>

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ២*

*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៦-២០៣ ប្រក

លិខិតចូល
ថ្ងៃទី ០៤ ខែ ... ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពីការកែសម្រួលប្រកាសស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧-០០-០៤ ប្រក ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦

## សំរេច

**ប្រការមួយ.-**

កែសម្រួលប្រការ ៩ នៃប្រកាសលេខធ៧-០០-០៤ប្រក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ មានដូចខាងក្រោម ÷

**ប្រការ៩ថ្មី.-**

ធនាគារជាតិនៃកម្ពុជា ផ្តល់អាជ្ញាប័ណ្ណមិនមានកំណត់រយៈពេលសុពលភាពចំពោះធនាគារពាណិជ្ជ ដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

**ប្រការពីរ.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការបី.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៦

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការពីរ " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

TIONAL BANK OF CAMBODIA

ber.......... .... ........................................

Unofficial Translation

# PRAKAS
# on
# Amendment to Prakas on Licensing of Commercial Banks

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244 of 7 September 2004 on the appointment of His Excellency **Chea Chanto** as Governor of the National Bank of Cambodia, as equivalent to Senior Minister;
- With reference to the PRAKAS No B700-04 on the Licensing of Banks on January 10, 2000;
- Pursuant to the recommendation made by the National Bank of Cambodia management during the September 04, 2006, meeting.

## DECIDES

### Article One

Amendment to Article 9 of Prakas No B700-04 on the Licensing of Banks on January 10, 2000, as follows:

### New Article 9

An indefinite license shall be provided by the National Bank of Cambodia to all commercial banks operating in the Kingdom of Cambodia.

### Article Two

The General Directorate, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking

and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article Three**

This Prakas shall have effect from the signing date.

Phnom Penh, September 13, 2006
**The Governor**
**Signed and sealed: Chea Chanto**

cc: - The Members of the Board of Directors
- The parties concerned as stated in Article Two
- File
- CM "for info"
- Administration of CM
"for publication in the National Gazette"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៦–២០៨ ប្រក

ទទួលចូល
ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ2006

## ប្រកាស
## ស្តីពីការកែសម្រួលប្រកាសស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧-០០-០៥ ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦

## សំរេច

**ប្រការមួយ.-**

កែសម្រួលប្រការ ៩ និងប្រការ ១៣ នៃប្រកាសលេខធ៧-០០-០៥ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ មានដូចខាងក្រោម ÷

**ប្រការ៩ថ្មី.-**

ធនាគារជាតិនៃកម្ពុជា ផ្តល់អាជ្ញាប័ណ្ណមិនមានកំណត់រយៈពេលសុពលភាពចំពោះធនាគារឯកទេសដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ១៣ថ្មី.-**

ធនាគារឯកទេស ដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុនស្មើនឹងប្រាំភាគរយ(៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដោយទទួលបានកំរៃការប្រាក់ដូចខាងក្រោម ÷

ក.ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀលទទួលបានកំរៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (១/២)នៃអត្រាការប្រាក់បុនហិរញ្ញប្បទាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ក្នុងរយ:ពេល៦ខែម្តង ។

ខ.ប្រាក់តំកល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេស ទទួលបានកំរៃការប្រាក់បីភាគប្រាំបី (៣/៨) នៃអត្រា SIBOR (Singapore Inter-Bank Offered Rate) ក្នុងរយ:ពេល៦ខែម្តង។ ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងទៅធនាគារទាំងអស់ ពីអត្រាការប្រាក់ ដែលបានអនុវត្តសំរាប់កាលកំណត់និមួយៗ ។

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះ នៅពេលធនាគារឯកទេសនោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្ត និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម ។

**ប្រការពីរ.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការបី.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០០៦

**ទេសាភិបាល**

ជា-ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការពីរ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណ:រដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណ:រដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7-06-208 Prokor

Unofficial Translation

# PRAKAS
# on
# Amendment to Prakas on Licensing of Specialized Banks

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244 of 7 September 2004 on the appointment of His Excellency **Chea Chanto** as Governor of the National Bank of Cambodia, as equivalent to Senior Minister;
- With reference to the PRAKAS No B700-05 on the Licensing of Rural Credit Specialized Banks on January 11, 2000;
- Pursuant to the recommendation made by the National Bank of Cambodia management during the September 04, 2006, meeting.

## DECIDES

**Article One**

Amendment to Article 9 and Article 13 of Prakas No B700-05 on the Licensing of Rural Credit Specialized Banks on January 11, 2000, as follows:

**New Article 9**

An indefinite license shall be provided by the National Bank of Cambodia to all specialized banks operating in the Kingdom of Cambodia.

**New Article 13**

A licensed specialized bank shall maintain an amount equal to five (5) percent of its registered capital in a permanent account with the National Bank of Cambodia, and be subject to the following conditions:

A. Deposits in Riel will bear interest at 1/2 of the refinancing rate set by the National Bank of Cambodia. The interest payment shall be settled semi-annually.

B. Deposits in foreign currency will bear interest at 3/8 SIBOR. The interest payment shall be settled semi-annually. The National Bank of Cambodia will notify all Specialized Banks of the applicable rate for the relevant period.

The National Bank of Cambodia will only reimburse the capital deposit to a licensed Specialized Bank if it voluntarily liquidates and has no deposit liabilities.

**Article two**

The General Directorate, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article Three**

This Prakas shall have effect from the signing date.

Phnom Penh, September 13, 2006
**The Governor**
**Signed and sealed: Chea Chanto**

cc: - The Members of the Board of Directors
- The parties concerned as stated in Article Two
- File
- CM "for info"
- Administration of CM
"for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៦-២០៩ ប្រក

ចុះបញ្ជី
ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៦

# ប្រកាស
## ស្តីពីការកែសម្រួលប្រកាសស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧-០០-០៦ ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦

**ស ម្រេ ច**

**ប្រការមួយ.-**

កែសម្រួលប្រការ ៩ និងប្រការ ១៣ នៃប្រកាសលេខធ៧-០០-០៦ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានដូចខាងក្រោម ÷

**ប្រការ៩ថ្មី.-**

ធនាគារជាតិនៃកម្ពុជា ផ្តល់អាជ្ញាប័ណ្ណមិនមានកំណត់រយៈពេលសុពលភាពចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ១៣ថ្មី.-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុនស្មើនឹងប្រាំភាគរយ(៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដោយទទួលបានកំរៃការប្រាក់ដូចខាងក្រោម:

ក.ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀលទទួលបានកំរៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (១/២)នៃអត្រាការប្រាក់បុនហិរញ្ញប្បទាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ក្នុងរយ:ពេល៦ខែម្តង ។

ខ.ប្រាក់តំកល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេសទទួលបានកំរៃការប្រាក់បីភាគប្រាំបី (៣/៨)នៃ អត្រា SIBOR (Singapore Inter-Bank Offered Rate) ក្នុងរយ:ពេល៦ខែម្តង ។ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងទៅគ្រឹះស្ថានទាំងអស់ពីអត្រាការប្រាក់ ដែលបានអនុវត្តសំរាប់កាលកំណត់និមួយៗ ។

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះនៅពេលគ្រឹះស្ថាននោះ ត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្ត.និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម ។

**ប្រការពីរ.-**

រាល់ការធ្វើវិសោធនកម្មលក្ខន្តិក: គ្រឹះស្ថានត្រូវបង់សោហ៊ុយចំនួនដប់ពាន់រៀល (១០.០០០រៀល) ក្នុងមួយទំព័រនៃលក្ខន្តិក: ដែលធ្វើវិសោធនកម្ម ។

**ប្រការបី.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការបួន.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ទេសាភិបាល**

**កន្លែងទទួល**

- ដូចប្រការបី " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណ:រដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណ:រដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.06 _ 209 Prokor

Unofficial Translation

# PRAKAS
# on
# Amendment to of Prakas on Licensing of microfinance Institutions

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244 of 7 September 2004 on the appointment of His Excellency **Chea Chanto** as Governor of the National Bank of Cambodia, as equivalent to Senior Minister;
- With reference to the PRAKAS No B700-06 on the Licensing of microfinancing Institutions on January 11, 2000;
- Pursuant to the recommendation made by the National Bank of Cambodia management during the September 04, 2006, meeting.

## DECIDES

**Article One**

Amendment to Article 9 and article 13 of Prakas No.B7.00-06 on the Licensing of microfinancing Institutions on January11, 2000, as follows:

**New Article 9**

An indefinite license shall be provided by the National Bank of Cambodia to all microfinance Institutions operating in the Kingdom of Cambodia.

**New Article 13**

A licensed microfinance Institutions shall maintain an amount equal to five (5) percent of its registered capital in a permanent account with the National Bank of Cambodia, and be subject to the following conditions:

A. Deposits in Riel will bear interest at 1/2 of refinancing rate set by the National Bank of Cambodia. The interest payment shall be settled semi-annually.

B. Deposits in foreign currency will bear interest at 3/8 SIBOR. The interest payment shall be settled semi-annually. The National Bank of Cambodia will notify all institutions of the applicable rate for the relevant period.

The National Bank of Cambodia will only reimburse the capital deposit to a licensed microfinance Institution if it voluntarily liquidates and has no deposit liabilities.

**Article Two**

A fee of KHR 10,000 shall be applied to Microfinance Institutions for each page of the Article of Association amended.

**Article Three**

The General Directorate, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article Four**

This Prakas shall have effect from the signing date.

Phnom Penh, September 13, 2006
**The Governor**
**Signed and sealed: Chea Chanto**

cc: - The Members of the Board of Directors
- The parties concerned as stated in Article Three
- File
- CM "for info"
- Administration of CM
"for publication in the National Gazette"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៦-២២០ ប្រ.ក

លិខិតចូល

ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពីការកែសម្រួលប្រកាសស្តីពី
## សោហ៊ុយបង្កើនដើមទុនសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាស អោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧៩៧-១៤៧ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីល័ក្ខខ័ណ្ឌសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦

## សំរេច

**ប្រការមួយ.-**

កែសម្រួល ចំណុច ៣.២ ប្រការ ៣ នៃប្រកាសលេខធ៧៩៧-១៤៧ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីល័ក្ខខ័ណ្ឌសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានដូចខាងក្រោម ÷

**ប្រការ៣ថ្មី.-**

៣.២ថ្មី.រាល់ការបង្កើនដើមទុន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ជាមុន។ ការបង្កើនដើមទុនត្រូវបង់សោហ៊ុយចំនួនសូន្យក្បៀសសូន្យបីភាគរយ (០,០៣%) លើចំនួនប្រាក់ដែលសុំបង្កើន ។

**ប្រការពីរ.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការបី.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៦

**ទេសាភិបាល**

ជា_ចាន់តូ

